សន្និសីទជាតិស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

បទបង្ហាញស្តីពី

# វឌ្ឍនភាព បញ្ហាប្រឈម និងសំណូមពររបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ

មជ្ឈមណ្ឌលសន្និបាតកោះពេជ្រ ថ្ងៃទី ២១-២២ ខែកុម្ភៈ ឆ្នាំ ២០១៨

បង្ហាញដោយឯកឧត្តម សយ កុសល
ប្រធានសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន

1

## ក្រុមប្រឹក្សារាជធានី ខេត្ត៖ វឌ្ឍនភាព

- ការបង្កើតបានសមាគមក្រុមប្រឹក្សារាជធានី ខេត្ត
- ការបង្កើតគណៈកម្មាធិការនានាតាមការកំណត់
- ការបង្កើតនិងការដាក់ឱ្យដំណើរការអង្គភាពច្រកចេញ ចូលតែមួយ
- ទំនាក់ទំនងល្អរវាងក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
- ការដាក់ចេញដីកា និងសេចក្តីសម្រេចផ្សេងៗ

2

## ក្រុមប្រឹក្សារាជធានី ខេត្តៈ វឌ្ឍនភាព (ត)

- ការរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាយ៉ាងទៀងទាត់
- ការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ជារៀងរាល់ឆ្នាំ
- ការរៀបចំកិច្ចប្រជុំសម្ងាត់ ដើម្បីវាយតម្លៃ តែងតាំង ផ្លាស់ប្តូរមន្ត្រី
- ការទទួលបានការបណ្តុះបណ្តាល

3

## ក្រុមប្រឹក្សារាជធានី ខេត្តៈ វឌ្ឍនភាព (ត)

- ការចូលរួមសកម្មភាពអភិវឌ្ឍន៍ សកម្មភាពសង្គម និងសកម្មភាពសាសនា
- គ.ក.ស.ក ទទួលបានថវិកាវិភាជន៍ពី ផអ៣
- ទំនាក់ទំនងល្អរវាងគណៈអភិបាលជាមួយក្រុមប្រឹក្សា និងរវាងមន្ទីរជំនាញជាមួយក្រុមប្រឹក្សា
- គណនេយ្យភាពរបស់គណៈអភិបាលមួយចំនួនចំពោះក្រុមប្រឹក្សា
- ការគាំទ្រការអនុវត្តមុខងារជាជម្រើសដែលបានលើកឡើងដោយគណៈអភិបាល
- ការជួយសម្រាលការលំបាកខ្លះរបស់គ្រួសារសពសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត តាមរយៈមូលនិធិមរណៈសង្គ្រោះរបស់សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត។

4

## ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់៖ វឌ្ឍនភាព

- ការទទួលបានការគាំទ្រពីសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន លើការធានារ៉ាប់រងសុខភាព និងការសម្រាលបុត្រ
- ការបង្កើតសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់នៅតាម រាជធានី ខេត្ត និងសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន
- ចាប់តាំងពីឆ្នាំ ២០០៦ មក សម្ព័ន្ធភាពជាតិ បានកៀរគរថវិកាប្រមាណ ១៥ លានដុល្លារអាមេរិកពីក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដើម្បីអនុវត្តសកម្មភាពបំរើសមាជិករបស់ខ្លួន

5

## ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់៖ វឌ្ឍនភាព (ត)

- ជំនួយរបស់សមាគមដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំវេទិកាជាមួយប្រជាពលរដ្ឋ និងវេទិកាជាមួយអ្នកពាក់ព័ន្ធនៅថ្នាក់ក្រុង ស្រុក ខេត្ត
- អន្តរាគមន៍របស់សមាគមដល់សមាជិកដែលជួបការលំបាកក្នុងការបំពេញការងារ
- ការជួយសម្រាលទុក្ខលំបាករបស់គ្រួសារសមាជិកក្រុមប្រឹក្សាដែលទទួលមរណភាពតាមរយៈមូលនិធិមរណៈសង្គ្រោះរបស់សមាគមក្រុមប្រឹក្សាក្រុង ស្រុកនៅតាមរាជធានី ខេត្តមួយចំនួន

6

## ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់៖ វឌ្ឍនភាព (ត)

- ការបណ្ដុះបណ្ដាលកសាងសមត្ថភាពដល់ក្រុមប្រឹក្សា
- ការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាលក្នុងការបង្កើនប្រាក់ឧបត្ថម្ភជូន និងសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ជាបន្តបន្ទាប់
- ការប្រជុំទៀងទាត់របស់ក្រុមប្រឹក្សា
- ការរៀបចំ និងអនុម័តគម្រោងថវិកាប្រចាំឆ្នាំ និងការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល

7

## ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់៖ វឌ្ឍនភាព (ត)

- ការអនុវត្តមូលនិធិក្រុង ស្រុក ឃុំ សង្កាត់
- ការរួមចំណែកអនុវត្តយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា
- ការអនុវត្តមុខងារជាជម្រើស និងមុខងារជាកាតព្វកិច្ចមួយចំនួន។

8

## ក្រុមប្រឹក្សារាជធានី ខេត្តៈ បញ្ហាប្រឈម

**ទំនាក់ទំនងអន្តររដ្ឋបាល និងទំនាក់ទំនងផ្ទៃក្នុងរដ្ឋបាល**

- ទំនាក់ទំនងរវាងក្រុមប្រឹក្សារាជធានី ខេត្តជាមួយក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នៅមានកម្រិត
- កត្តាសមត្ថភាព និងឆន្ទៈទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំ និងមន្ត្រីមួយចំនួនមិនស្របនឹងទំហំការងារក្នុងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- ការអនុវត្តសេចក្តីសម្រេច ឬការណែនាំមួយចំនួនរបស់ក្រុមប្រឹក្សាដល់អង្គភាពពាក់ព័ន្ធនៅមិនទាន់បានល្អ។

9

## ក្រុមប្រឹក្សារាជធានី ខេត្តៈ បញ្ហាប្រឈម (ត)

**គណនេយ្យភាពរបស់គណៈអភិបាល និងមន្ទីរជំនាញនានាចំពោះក្រុមប្រឹក្សារាជធានី ខេត្ត**

- គណៈកម្មាធិការបច្ចេកទេសប្រជុំមិនបានទៀងទាត់
- ភាគីពាក់ព័ន្ធមួយចំនួនមិនបានយកចិត្តទុកដាក់ចូលរួមជាមួយក្រុមការងារបច្ចេកទេស
- ការចែករំលែកលិខិតបទដ្ឋានគតិយុត្ត សេចក្តីណែនាំ នីតិវិធីនានាដល់សមាជិកក្រុមប្រឹក្សានៅមិនទាន់បានទូលំទូលាយ។

10

## ក្រុមប្រឹក្សារាជធានី ខេត្តៈ បញ្ហាប្រឈម (ត)

**ការអនុវត្តមុខងារជាជម្រើស និងមុខងារជាកាតព្វកិច្ច**

- ពុំទាន់មានបញ្ជីមុខងារជាជម្រើសច្បាស់លាស់សម្រាប់ណែនាំឱ្យក្រុមប្រឹក្សាអនុវត្ត
- ថវិកានៅមានកម្រិតក្នុងការអនុវត្តមុខងារជាកាតព្វកិច្ច។
- ការអនុវត្តមុខងារជាជម្រើសពុំទាន់អាចផ្តួចផ្តើម និងអនុវត្តបាន ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ដោយសារខ្វះមធ្យោបាយសម្រាប់អនុវត្ត។

11

## ក្រុមប្រឹក្សារាជធានី ខេត្តៈ បញ្ហាប្រឈម (ត)

**ការរៀបចំកិច្ចប្រជុំ វេទិការបស់ក្រុមប្រឹក្សា និងវគ្គបណ្តុះបណ្តុះបណ្តាល**

- ការផ្សព្វផ្សាយព័ត៌មាន និងលទ្ធផលកិច្ចប្រជុំ មិនទាន់បានទូលំទូលាយ បានត្រឹមតែបិទផ្សាយលើបញ្ជរព័ត៌មានមុខសាលាខេត្ត និងចែកជូនសមាជិកអង្គប្រជុំ
- ការចូលរួមក្នុងវគ្គបណ្តុះបណ្តាលនៅថ្នាក់ក្រុង ស្រុក មិនបានពេញលេញ និងមិនសូវមានប្រសិទ្ធភាព។

12

## ក្រុមប្រឹក្សារាជធានី ខេត្តៈ បញ្ហាប្រឈម (ត)

**ការគ្រប់គ្រងបុគ្គលិក**

- ការបែងចែកភារកិច្ចជូនមន្ត្រីរាជការមិនស្របតាមជំនាញ
- ការតំឡើងឋានន្តរសក្តិ និងថ្នាក់ជូនមន្ត្រីរាជការ មិនស្របតាមលំដាប់ថ្នាក់ និងពេលវេលា
- ការលើកទឹកចិត្តមន្ត្រីរាជការ តាមរយៈការជូនគ្រឿងឥស្សរិយយស មិនបានវិនិច្ឆ័យលក្ខណៈសម្បត្តិត្រឹមត្រូវ
- ការផ្តល់នីត្យានុកូលភាពលើដីកាតែងតាំង ផ្ទេរ និងប្រគល់ភារកិច្ចរបស់ក្រសួងស្ថាប័នមួយចំនួនមានការយឺតយ៉ាវ

13

## ក្រុមប្រឹក្សារាជធានី ខេត្តៈ បញ្ហាប្រឈម (ត)

**ការគ្រប់គ្រងបុគ្គលិក**

- ការតែងតាំងមន្ត្រីតាមមន្ទីរមួយចំនួន ខ្វះការវិនិច្ឆ័យឱ្យបានត្រឹមត្រូវមុននឹងដាក់ជូនក្រុមប្រឹក្សាអនុម័ត
- ការតែងតាំងមន្ត្រីតាមនីតិវិធីរបស់អង្គភាពនៅខ្វះចន្លោះដោយសារតែមន្ទីរខ្លះមិនទាន់យល់ច្បាស់អំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- មិនមានថវិកាគាំទ្រពីលេខាធិការដ្ឋាន គ.ជ.អ.ប មករាជធានី ខេត្ត ក្រុង ស្រុកបន្តទៀត។ បច្ចុប្បន្នទីប្រឹក្សា និងបុគ្គលិកកិច្ចសន្យារបស់ផអ ៣ ត្រូវបានបញ្ឈប់
- នៅដំណើរការមិនទាន់បានល្អ ជាពិសេសការវាយតម្លៃលើការអនុវត្តការងាររបស់បុគ្គលិក
- សមត្ថភាព និងជំនាញរបស់មន្ត្រីមួយចំនួននៅមានកម្រិត។

14

## ក្រុមប្រឹក្សារាជធានី ខេត្តៈ បញ្ហាប្រឈម (ត)

**កម្មវិធីវិនិយោគបីឆ្នាំរំកិល និងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ**

- ការលើកគម្រោងមានច្រើន ប៉ុន្តែការគាំទ្រមានតិច
- ក្រុង ស្រុក ឃុំ សង្កាត់ ផ្តល់ធាតុចូលសម្រាប់ការកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីបីឆ្នាំរំកិលមានការយឺតយ៉ាវ
- ក្រុង ស្រុក ឃុំ សង្កាត់មិនយកចិត្តទុកដាក់ក្នុងការរៀបចំកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលដោយសារមានការងារច្រើន
- ការប្រមូលធាតុចូលពីបណ្តាមន្ទីរ អង្គភាពនានាជុំវិញខេត្ត ក្រុង និងស្រុក មិនទាន់ចំបញ្ហា និងមិនទាន់ពេលវេលា
- ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ មិនអាចសម្រេចបានតាមគោលបំណង គោលដៅ និងចក្ខុវិស័យអភិវឌ្ឍន៍ដែលបានអនុវត្តដោយក្រុមប្រឹក្សា។

15

## ក្រុមប្រឹក្សារាជធានី ខេត្តៈ បញ្ហាប្រឈម (ត)

**គម្រោងថវិកាប្រចាំឆ្នាំ និងក្របខណ្ឌចំណាយរយៈពេលមធ្យម**

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មិនបានណែនាំរបៀបរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម
- មិនទាន់យល់ច្បាស់ពីនីតិវិធីគ្រោងផែនការ និងការចំណាយ
- ការទទួលថវិកាមិនទាន់ពេលវេលា មិនឆ្លើយតបទៅនឹងតម្រូវការប្រតិបត្តិការ
- គម្រោងថវិកាប្រចាំឆ្នាំដែលក្រុមប្រឹក្សាបានអនុម័តរួចហើយ ត្រូវយកទៅកែប្រែនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុម្តងទៀត
- អង្គភាពពន្ធដារប៉ាន់ប្រមាណចំណូលតាមគម្រោងរបស់ខេត្ត មិនជាក់លាក់ដែលធ្វើឱ្យមានអតិរេកបង់ចូលថវិកាជាតិ នាំឱ្យការចំណាយសម្រាប់គុណប្រយោជន៍ខេត្តបន្ថែម មានការខ្វះខាត។

16

## ក្រុមប្រឹក្សារាជធានី ខេត្តៈ បញ្ហាប្រឈម (ត)

**ការអនុវត្តគណនេយ្យភាពសង្គម**

- ខ្វះផ្ទាំងផ្សព្វផ្សាយកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ
- ការយល់ដឹងរបស់វិស័យទាំងបីលើការអនុវត្តគណនេយ្យភាពសង្គមនៅមានកម្រិត
- ប្រជាពលរដ្ឋមិនចាប់អារម្មណ៍លើការអនុវត្តគណនេយ្យភាពសង្គម
- ការបំពេញព័ត៌មានមិនបានពេញលេញ
- នៅមានការយកកម្រៃក្រៅផ្លូវការចំពោះសេវាដែលជាតម្រូវការជាមូលដ្ឋាន។

17

## ក្រុមប្រឹក្សារាជធានី ខេត្តៈ បញ្ហាប្រឈម (ត)

**ការអនុវត្តការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន**

- បញ្ហាផលិតកម្មកសិកម្ម និងតម្លៃផលិតផលកសិកម្ម
- ក្រុមប្រឹក្សាមិនមានបទពិសោធន៍លើការងារអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាន
- មិនមានថវិកាសម្រាប់អនុវត្តសកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាន
- មិនមានព័ត៌មានអំពីសក្តានុពលសេដ្ឋកិច្ចមូលដ្ឋាន។

18

## ក្រុមប្រឹក្សារាជធានី ខេត្តៈ បញ្ហាប្រឈម(ត)

**ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ**

- ទ្រព្យសម្បត្តិចាស់ទ្រុឌទ្រោម មិនមានថវិកាសម្រាប់ជួសជុល
- មានការរំលោភដីរដ្ឋ
- ទំហំដីជាក់ស្តែងតូចជាងក្នុងបញ្ជីសារពើភ័ណ្ឌ
- ការយឺតយ៉ាវក្នុងការរៀបចំបញ្ជីសារពើភ័ណ្ឌ ដោយសារការផ្លាស់ប្តូរទម្រង់បែបបទញឹកញាប់។

19

## ក្រុមប្រឹក្សារាជធានី ខេត្តៈ បញ្ហាប្រឈម (ត)

**ការឆ្លើយតបតម្រូវការរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន**

- ទោះបីជាថវិកាខេត្តមានការកើនឡើងក្តី ក៏នៅតែមិនអាចឆ្លើយតបបានទៅនឹងតម្រូវការអភិវឌ្ឍន៍មូលដ្ឋានដែលបានលើកឡើងដោយប្រជាពលរដ្ឋក្នុងវេទិកានានា និងក្នុងពេលដំណើរការកម្មវិធីវិនិយោគបីឆ្នាំរំកិលផងដែរ។

20

## ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់៖ បញ្ហាប្រឈម

**ទំនាក់ទំនងអន្តររដ្ឋបាល និងទំនាក់ទំនងផ្ទៃក្នុងរដ្ឋបាល**

- ទំនាក់ទំនងរវាងគណៈអភិបាលជាមួយក្រុមប្រឹក្សាក្រុង ស្រុកនៅមិនទាន់រលូន
- គណៈអភិបាលដាក់ឯកសារឱ្យក្រុមប្រឹក្សាពិនិត្យ និងអនុម័តដោយមានការយឺតយ៉ាវ ហើយមិនបានសិក្សា ពិនិត្យឱ្យបានហ្មត់ចត់។
- គណៈអភិបាល និងក្រុមប្រឹក្សាបំពេញការងារមិនស៊ីសង្វាក់គ្នា
- គណៈអភិបាល មិនសូវមានគណនេយ្យភាពជាមួយក្រុមប្រឹក្សា
- ការងារទំនាក់ទំនងរវាងក្រុមប្រឹក្សា និងគណៈអភិបាល ព្រមទាំងបុគ្គលិកដទៃទៀត ពុំទាន់មានសង្គតិភាពទៅនឹងផ្លូវច្បាប់

21

## ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់៖ បញ្ហាប្រឈម (ត)

**ទំនាក់ទំនងអន្តររដ្ឋបាល និងទំនាក់ទំនងផ្ទៃក្នុងរដ្ឋបាល**

- ស្មៀនឃុំ សង្កាត់មួយចំនួន ពុំបានអនុវត្តតាមការណែនាំរបស់មេឃុំ ចៅសង្កាត់ និងក្រុមប្រឹក្សា
- មេឃុំមួយចំនួន អវត្តមាន ឬ មានបេសកកម្ម ពុំមានការផ្ទេរសិទ្ធជាផ្លូវការ
- ប៉ុស្តិ៍រដ្ឋបាលមួយចំនួន ពុំសហការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់
- ឃុំ សង្កាត់ មួយចំនួនដែលស្មៀនមានបញ្ហា ក្រុមប្រឹក្សាស្នើសុំផ្លាស់ប្តូរ ប៉ុន្តែសាលាក្រុង ស្រុក ពុំមានស្មៀនបំរុងសម្រាប់ផ្លាស់ប្តូរ
- ការយល់ដឹងរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់មួយចំនួននៅមានកម្រិត ពីព្រោះពីមួយអាណត្តិទៅមួយអាណត្តិ មានការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ថ្មី

22

## ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់៖ បញ្ហាប្រឈម (ត)

**គណនេយ្យភាពរបស់គណៈអភិបាល ការិយាល័យជំនាញនានាចំពោះក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងប្រជាពលរដ្ឋ**

- ការិយាល័យជំនាញមួយចំនួន គោរពតាមការណែនាំរបស់ខ្សែបណ្ដោយខ្លួន ជាងការណែនាំរបស់ក្រុមប្រឹក្សា
- គណៈអភិបាលក្រុងស្រុកមួយចំនួននៅមិនទាន់គិតថា គាត់មានគណនេយ្យភាពជាមួយក្រុមប្រឹក្សា
- គណៈអភិបាលមិនបានរាយការណ៍អំពីការចំណាយ និងសកម្មភាពរបស់ខ្លួននៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា
- ការិយាល័យជំនាញមួយចំនួនមិនមកចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាក្រុង ស្រុក
- ក្រុមប្រឹក្សាស្រុក មិនមានថវិកាសម្រាប់ចុះជួយប្រជាពលរដ្ឋ

23

## ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់៖ បញ្ហាប្រឈម (ត)

**ការអនុវត្តមុខងារជាជម្រើស និងមុខងារជាកាតព្វកិច្ច**

- មុខងារដែលបានផ្ទេរមួយចំនួន មិនទាន់បានអនុវត្ត ដោយសារខ្វះធនធាន និងបច្ចេកទេស
- ការអនុវត្តការងាររបស់គណៈអភិបាលមួយចំនួន មិនបានឆ្លងក្រុមប្រឹក្សាទេ
- ការអនុវត្តមុខងារជាជម្រើស បានតិចតួចបំផុតដោយសារខ្វះធនធាន និងលទ្ធភាព
- រដ្ឋបាលក្រុង ស្រុក នៅមិនទាន់អនុវត្តមុខងារជាកាតព្វកិច្ចបានគ្រប់ជ្រុងជ្រោយនៅឡើយ
- ការអនុវត្តមុខងារជាជម្រើស មាននីតិវិធីស្មុគស្មាញ (ដូចជាសេវាប្រមូលសំរាម)
- ក្រុមប្រឹក្សាឃុំ សង្កាត់ ទទួលបានវិភាជន៍មានកម្រិតពីរាជរដ្ឋាភិបាល ដូច្នេះ មិនមានលទ្ធភាពពេញលេញក្នុងការអនុវត្តមុខងារជាជម្រើស។

24

ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់៖ បញ្ហាប្រឈម (ត)

**ការរៀបចំកិច្ចប្រជុំ វេទិការបស់ក្រុមប្រឹក្សា និងវគ្គបណ្តុះបណ្តាល**

- របៀបរបបប្រជុំក្រុមប្រឹក្សានៅមិនទាន់បានល្អ ដូចជាការរៀបចំរបៀបវារៈ របាយការណ៍ និងកំណត់ហេតុកិច្ចប្រជុំ។
- មិនមានម្ចាស់អាជីវកម្ម អង្គការសង្គមស៊ីវិល វិស័យឯកជន និងប្រជាពលរដ្ឋចូលរួមនៅក្នុងកិច្ចប្រជុំនៅថ្នាក់ក្រុង ស្រុក។ ការបិទផ្សាយប្រក្រតិទិនកិច្ចប្រជុំនៅតាមទីសាធារណៈ មិនទាន់បានទូលំទូលាយ រីឯការផ្សាយលទ្ធផលនៃកិច្ចប្រជុំ ក៏មិនទាន់ល្អដែរ
- រដ្ឋបាលមានធនធានថវិកាមានកំណត់ ដោយអាចរៀបចំវេទិកាបានតែពីរ ឬបីកន្លែងប៉ុណ្ណោះក្នុងមូលដ្ឋានក្រុង ស្រុករបស់ខ្លួន
- វគ្គបណ្តុះបណ្តាលនៅថ្នាក់ក្រុង ស្រុក ធ្វើបានតិចតួចដោយខ្វះថវិកា។

25

ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់៖ បញ្ហាប្រឈម (ត)

**ការរៀបចំកិច្ចប្រជុំ វេទិការបស់ក្រុមប្រឹក្សា និងវគ្គបណ្តុះបណ្តាល**

- រដ្ឋបាលឃុំ សង្កាត់មួយចំនួនពុំបានរៀបចំវេទិកាសាធារណៈរបស់ខ្លួនជាមួយប្រជាពលរដ្ឋ។
- កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ នៅខ្វះការចូលរួមរបស់ដៃគូពាក់ព័ន្ធ ដូចជា ក្រុមប្រឹក្សាថ្នាក់ផ្សេងទៀត ដៃគូអភិវឌ្ឍន៍ក្នុងមូលដ្ឋាន។
- ឱកាសសួរសំណួរ សំណើ សំណូមពរ បញ្ហាប្រឈមនានា និងពិភាក្សារួមក្នុងអង្គវេទិកាមានរយៈពេលខ្លី
- ថវិកាគាំទ្រដំណើរការប្រជុំ និងវេទិការបស់ក្រុមប្រឹក្សាមានស្តួចស្តើង (នេះជាការងារអាទិភាពមួយក្នុងចំណោមកិច្ចការដទៃទៀត)។
- ក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ មួយចំនួន មានវ័យចំណាស់ និង ចំណេះដឹងមូលដ្ឋានមានកំរិត ពិបាកទទួលយកចំណេះដឹងថ្មី មេរៀនមានលក្ខណៈបច្ចេកទេស។

26

## ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់៖ បញ្ហាប្រឈម (ត)

**ការរៀបចំកិច្ចប្រជុំ វេទិការបស់ក្រុមប្រឹក្សា និងវគ្គបណ្តុះបណ្តាល**

- កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់មួយចំនួន ផ្លាស់ប្តូរពេលវេលាញឹកញាប់ពេកដែលធ្វើឱ្យក្រុមប្រឹក្សាក្រុង ស្រុក មានការលំបាកក្នុងការចាត់តំណាងទៅចូលរួម។
- ការបណ្តុះបណ្តាលសមាជិកក្រុមប្រឹក្សាពឹងផ្អែកតែទៅលើការគាំទ្ររបស់ ជអ៣ ដូច្នេះនៅមិនទាន់គ្រប់គ្រាន់ទេ។
- ចំណេះដឹងដែលទទួលបានពីការបណ្តុះបណ្តាលពិបាកនឹងយកទៅអនុវត្ត ពីព្រោះការបណ្តុះបណ្តាលមានលក្ខណៈទ្រឹស្តីពេក។

27

## ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់៖ បញ្ហាប្រឈម (ត)

**ការគ្រប់គ្រងបុគ្គលិក**

- បុគ្គលិករបស់ក្រុមប្រឹក្សាគោរពតាមការណែនាំរបស់គណៈអភិបាលជាងការណែនាំរបស់ក្រុមប្រឹក្សា
- បញ្ហាខ្វះមន្ត្រីធ្វើការនៅសាលាក្រុង ស្រុកនិងការតែងតាំងមន្ត្រីក្នុងមុខដំណែងមានការយឺតយ៉ាវ
- មានសេចក្តីសម្រេចបែងចែកតួនាទី ភារកិច្ចរបស់មន្ត្រីសាលាក្រុង ស្រុក រួចហើយ តែពេលអនុវត្តនៅតែច្របូលច្របល់
- ស្មៀនឃុំ សង្កាត់មួយចំនួន មិនមានស្មារតីវិជ្ជាជីវៈក្នុងការបំរើការងាររបស់ខ្លួន
- យកម៉ោងបំរើការងាររដ្ឋទៅធ្វើការងារឯកជន

28

ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់៖ បញ្ហាប្រឈម(ត)

**កម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ**

- ការរៀបចំកសាងផែនការអភិវឌ្ឍន៍នៅថ្នាក់ក្រុង ស្រុក ពុំមានជំហានដែលត្រូវពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋផ្ទាល់ ដូចថ្នាក់ឃុំ សង្កាត់
- ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ មានសំណើគម្រោងជាច្រើនតាមការលើកឡើងរបស់ប្រជាពលរដ្ឋតែឃុំ សង្កាត់ មានលទ្ធភាពតិចក្នុងការអនុវត្តគម្រោងទាំងនេះ ដែលធ្វើឱ្យប្រជាពលរដ្ឋលែងមានបំណងចូលរួមកសាងផែនការ និងកម្មវិធីវិយោគប្រចាំឆ្នាំ
- ការចូលរួមរបស់មន្ទីរ និងអង្គការ NGO នៅក្នុងសមាហរណកម្មផែនការ មានការថយចុះ
- នីតិវិធីថ្មីៗ សម្រាប់ផែនការអភិវឌ្ឍន៍ប្រាំឆ្នាំធ្វើឱ្យឃុំមានការលំបាកច្រើនដោយសារមិនទាន់យល់ដឹង។

29

ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់៖ បញ្ហាប្រឈម (ត)

**គម្រោងថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម**

- ការចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុកមួយចំនួនសម្រាប់ក្រុមប្រឹក្សា និងអង្គប្រតិបត្តិមិនទាន់បានគ្រោងចូលទៅក្នុងទម្រង់ថវិកា ជាពិសេសលើការចំណាយលើរៀបចំវេទិកាពិគ្រោះយោបល់ ការចុះគាំទ្ររដ្ឋបាលឃុំ សង្កាត់
- ការបង់ពន្ធប្រថាប់ត្រា ចូលថវិកាជាតិ ត្រូវប្រើពេលវេលា និង ការចំណាយសោហ៊ុយ ដែលត្រូវមកបង់ពន្ធនៅសាខាពន្ធដារខេត្ត។
- ក្នុងការរៀបចំគម្រោងថវិកាក្រុង ស្រុក និងឃុំ សង្កាត់ប្រចាំឆ្នាំ មានតែមន្ត្រី ២ ឬ ៣ នាក់ប៉ុណ្ណោះជាអ្នករៀបចំ ហើយសុំការអនុម័តពីក្រុមប្រឹក្សាតែម្តង។

30

ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់៖ បញ្ហាប្រឈម (ត)

**គម្រោងថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម**

- ការរៀបចំទម្រង់ថវិកាឃុំ សង្កាត់ច្រើនតែពឹងទៅលើស្មៀន ហើយពេលខ្លះពឹងផ្អែកលើមន្ត្រីរតនាគារ។
- ការទម្លាក់ថវិកាមិនទាន់ពេលវេលា សម្រាប់ទូទាត់អោយអ្នកទទួលការ។
- អូសបន្លាយពេលវេលាដេញថ្លៃគម្រោង។
- គម្រោងថវិកាខ្លះខ្វង់ខ្លះមិនឆ្លើយតបនឹងតម្រូវការចំណាយរបស់មូលដ្ឋាន(អនុគណនីខ្លះមិនមែនជាតម្រូវការរបស់មូលដ្ឋាន តែក្រសួងហិរញ្ញវត្ថុបានកំណត់ឱ្យចាយ)។
- មិនចាំលេខកូដ និងមិនសូវយល់ពីប្រព័ន្ធគណនេយ្យច្បាស់លាស់។

31

ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់៖ បញ្ហាប្រឈម (ត)

**ការអនុវត្តគណនេយ្យភាពសង្គម**

- មិនទាន់បានអនុវត្តនៅគ្រប់ក្រុង ស្រុក។
- ការផ្តល់របាយការណ៍របស់វិស័យពាក់ព័ន្ធមករដ្ឋបាលស្រុកមានការយឺតយ៉ាវ។
- ការបិទផ្សាយផ្ទាំងព័ត៌មានពុំសូវមានការចាប់អារម្មណ៍ពីប្រជាពលរដ្ឋ
- មន្ត្រីបង្គោលស្រុកខ្លះ មិនបានរៀបចំផែនការសកម្មភាពច្បាស់លាស់ផ្ញើមកថ្នាក់ខេត្ត ដើម្បីចុះជួយគាំទ្រលើការបិទផ្សាយផ្ទាំងព័ត៌មាននៅតាមឃុំ សាលារៀន និង មណ្ឌលសុខភាព ។

32

## ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់៖ បញ្ហាប្រឈម (ត)

**ការអនុវត្តគណនេយ្យភាពសង្គម**

- ការប្រមូលទិន្នន័យទាំង ៣ (សាលាឃុំ មណ្ឌលសុខភាព និងសាលារៀន) មានភាពយឺតយ៉ាវ។
- ពុំបានបំពេញព័ត៌មានគ្រប់គ្រាន់ ព័ត៌មានមួយចំនួនក្នុងគំរូរបាយការណ៍ពិបាកបំពេញ។
- ការបង្ហាញព័ត៌មាន និងការអនុវត្តមិនស៊ីសង្វាក់ (នៅមានការលាក់លៀម)

33

## ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់៖ បញ្ហាប្រឈម (ត)

**ការអនុវត្តការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន**

- មានការលំបាកក្នុងការផ្លាស់ប្តូរផ្នត់គំនិតរបស់ប្រជាពលរដ្ឋ និងខ្វះធនធានសម្រាប់ប្រើប្រាស់
- ថវិកាក្នុងការអនុវត្តគម្រោងនៅមានកម្រិត
- រដ្ឋបាលនៅថ្នាក់ក្រោមជាតិមិនទាន់យល់ស៊ីជម្រៅអំពីគម្រោងអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន (ទាំងប្រជាពលរដ្ឋ និង អាជ្ញាធរ)
- រដ្ឋបាលមូលដ្ឋានខ្វះការយកចិត្តទុកដាក់ក្នុងការថែរក្សា និង លើកទឹកចិត្តអាជីវកម្មខ្នាតតូច
- ប្រជាពលរដ្ឋ មិនមានទំនុកចិត្តក្នុងការបង្កបង្កើនផលដោយសារមិនមានទីផ្សារផលិតផល

34

## ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់៖ បញ្ហាប្រឈម (ត)

**ការអនុវត្តការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន**

- ចំណេះដឹងអំពីការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន មិនទាន់បានជ្រួតជ្រាបដល់អ្នកដឹកនាំ និងប្រជាពលរដ្ឋនៅមូលដ្ឋាននៅឡើយ
- ប្រជាជនពិបាករកការងារធ្វើនៅក្នុងមូលដ្ឋាន ប្រជាពលរដ្ឋធ្វើចំណាកស្រុក
- ប្រជាពលរដ្ឋខ្វះថវិកាបង្កើតមុខរបរក្រោយពេលរៀនជំនាញចប់
- ក្រុមប្រឹក្សាមានគំនិតក្នុងការរៀបចំជាសមាគមផ្សេងៗ ទៅតាមមុខសញ្ញាផលិតផលក្នុងមូលដ្ឋាន តែការគាំទ្រក្នុងការអនុវត្តមិនទាន់បានល្អ មិនទាន់ពេញលេញ។

35

## ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់៖ បញ្ហាប្រឈម (ត)

**ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ**

- ពេលអនុវត្តគម្រោងនីមួយៗ ប្រជាពលរដ្ឋទាមទារច្រើនលើការសងផលប៉ះពាល់
- មិនទាន់កំណត់ព្រំប្រទល់ឃុំបានច្បាស់លាស់
- ការសាងសង់លើចិញ្ចើមផ្លូវសាធារណៈ
- មន្ត្រីបរិស្ថានកំណត់ព្រំប្រទល់ដីព្រៃអភិរក្សជាមួយដីសហគមន៍មិនច្បាស់លាស់ បង្កបញ្ហាចំរូងចំរាស់ជាមួយប្រជាពលរដ្ឋ។

36

## ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់៖ បញ្ហាប្រឈម (ត)

**ការឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន**

- ប្រជាពលរដ្ឋដែលមកទទួលសេវាពីរដ្ឋបាលក្រុង ស្រុក ពេលខ្លះត្រូវចំណាយពេលយូរក្នុងការទទួលបានសេវា ដោយសេវាខ្លះទាមទារឱ្យមានលក្ខណៈបច្ចេកទេសចុះសិក្សា ឬស្រាវជ្រាវ
- ការកែតម្រូវទិន្នន័យខុសក្នុងអត្រានុកូលដ្ឋាន នៅតែប្រើរយៈពេលយូរ និងស្មុគ្រស្មាញ
- ការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជូនប្រជាពលរដ្ឋប្រើរយៈពេលយូរ
- ការសុំលិខិតឆ្លងដែន ត្រូវចំណាយថវិកាច្រើន និងប្រើពេលវេលាយូរ(ទៅធ្វើនៅភ្នំពេញ)

37

## ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់៖ បញ្ហាប្រឈម (ត)

**ការឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន**

- ក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ មិនទាន់មានលទ្ធភាពពេញលេញក្នុងការឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋដោយសារថវិការបស់ក្រុង ស្រុក ឃុំ សង្កាត់ មានចំនួនតិច។
- សំណូមពររបស់ប្រជាពលរដ្ឋហួសពីសមត្ថភាពដោះស្រាយរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

38

## ក្រុមប្រឹក្សារាជធានី ខេត្តៈ សំណូមពរ

- សំណូមពរបង្កើនថវិកា គ.ក.ស.ក ឱ្យបានច្រើនជាងនេះ
- ស្នើសុំថ្នាក់ជាតិណែនាំអំពីពេលវេលាឱ្យបានច្បាស់លាស់ក្នុងការបន្សុំកម្មវិធីវិនិយោគបីឆ្នាំរំកិល និងផែនការថវិកាប្រចាំឆ្នាំ
- ស្នើសុំថ្នាក់ជាតិផ្តល់ការគាំទ្រដល់ក្រុមប្រឹក្សាក្នុងការរៀបចំផែនការអនុវត្តន៍មុខងារជាជម្រើស
- ថ្នាក់ជាតិ គួរផ្តល់ការគាំទ្រដល់ក្រុមប្រឹក្សាក្នុងការអនុវត្តមុខងារជាជម្រើស
- ថ្នាក់ជាតិ គួរពិនិត្យផ្ទេរមុខងារមករដ្ឋបាលថ្នាក់ក្រោមជាតិបន្ថែមទៀត ដោយភ្ជាប់មកជាមួយនូវធនធានមនុស្ស ថវិកា និងគោលការណ៍ណែនាំប្រតិបត្តិការ

39

## ក្រុមប្រឹក្សារាជធានី ខេត្តៈ សំណូមពរ (ត)

- សំណូមពររាជរដ្ឋាភិបាលឱ្យក្រុមប្រឹក្សាមានមធ្យោបាយសម្រាប់ប្រើប្រាស់ក្នុងការចុះមូលដ្ឋានជួបប្រជាពលរដ្ឋ
- រដ្ឋបាលខេត្តបន្តវិភាជន៍ថវិកាគាំទ្រ គ.ក.ស.ក ខេត្ត និង គ.ក.ស.ក ក្រុង ស្រុក ក្នុងខណៈដែល ផអ៣ បានផ្អាកការគាំទ្រថវិកា
- រដ្ឋបាលខេត្ត គួរពិនិត្យលទ្ធភាពក្នុងការគាំទ្របុគ្គលិកជំនួយបច្ចេកទេសមួយចំនួន ដូចជាអ្នកបច្ចេកទេសគូសប្លង់ និងអ្នកបច្ចេកទេសអភិវឌ្ឍន៍សមត្ថភាព
- ស្នើសុំឱ្យមានវគ្គបណ្តុះបណ្តាលខ្លីៗ ពាក់ព័ន្ធទៅនឹងចំណេះដឹង និងតួនាទី ភារកិច្ចរបស់សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ថ្មី

40

## ក្រុមប្រឹក្សារាជធានី ខេត្តៈ សំណូមពរ (ត)

- ស្នើសុំបន្តគាំទ្រការកសាងសមត្ថភាពសមាជិកក្រុមប្រឹក្សា
- គួរមានទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ទាំងក្នុង និងក្រៅប្រទេសសម្រាប់ក្រុមប្រឹក្សាទាក់ទងនឹងការដឹកនាំ គ្រប់គ្រង និងចាត់ចែងការងារទូទៅរបស់រដ្ឋបាលខេត្ត
- ស្នើសុំឱ្យមានការចែករំលែកបទពិសោធន៍រវាងសមាជិកសមាគមក្រុមប្រឹក្សាតាមតំបន់តាមរយៈការប្តូរវេនតាមខេត្ត
- ស្នើសុំបង្កើនចំនួនស្ត្រីជាថ្នាក់ដឹកនាំ ក្រុង ស្រុក និង មន្ទីរជំនាញជុំវិញខេត្ត

41

## ក្រុមប្រឹក្សារាជធានី ខេត្តៈ សំណូមពរ (ត)

- ជម្រុញការៀបចំថ្នាក់ដឹកនាំជាស្ត្រីក្នុងតួនាទីជាប្រធាន អនុប្រធានមន្ទីរ ប្រធាន អនុប្រធានការិយាល័យដែលមិនទាន់មានក្នុងអង្គភាពនោះ
- ស្នើរក្សាតំណែងថ្នាក់ដឹកនាំជាស្ត្រីជូនស្ត្រីវិញក្នុងពេលគាត់ចូលនិវត្ត ឬមានការផ្លាស់ប្តូរកន្លែងធ្វើការ
- ស្នើបង្កើនប្រាក់ឧបត្ថម្ភសម្រាប់សមាជិកក្រុមប្រឹក្សា ឱ្យមានជីវភាពសមស្រប
- ស្នើសុំផ្តល់គ្រឿងឥស្សរិយយសដល់សមាជិក សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត
- ស្នើសុំរាជរដ្ឋាភិបាលផ្តល់ការគាំទ្រដល់សមាគមជាតិក្នុងការផ្តល់សេវាដល់សមាជិករបស់ខ្លួន។

42

## ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់៖ សំណូមពរ (ត)

- ស្នើសុំរាជរដ្ឋាភិបាល ផ្តល់ការគាំទ្រដល់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន និងសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់នៅតាមរាជធានី ខេត្ត ក្នុងការផ្តល់សេវាដល់សមាជិក
- ស្នើសុំរាជរដ្ឋាភិបាល ជួយផ្តល់កន្លែងធ្វើការក្រុមប្រឹក្សាក្រុង ស្រុក
- ស្នើសុំរាជរដ្ឋាភិបាល ជួយសាងសង់អគាររដ្ឋបាលឃុំ សង្កាត់ដែលមិនទាន់មាន
- សុំឱ្យក្រុមប្រឹក្សាមានទីប្រឹក្សា ឬជំនួយការដែលធ្វើការផ្ទាល់ជាមួយក្រុមប្រឹក្សា
- សូមអោយថ្នាក់ជាតិបន្ថែមថវិកាពីខេត្តដល់ក្រុង ស្រុក ដើម្បីអនុវត្តសកម្មភាពគណនេយ្យភាពសង្គម

43

## ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់៖ សំណូមពរ (ត)

- សុំបង្កើតខ្ទង់ថវិកាសម្រាប់ឱ្យក្រុមប្រឹក្សាចុះធ្វើការងារផ្ទាល់ជាមួយប្រជាពលរដ្ឋ
- សំណូមពរថ្នាក់ជាតិ ជួយផ្តល់ថវិកាសម្រាប់ឯកសណ្ឋាន និងសញ្ញាស័ក្ត ដល់ក្រុមប្រឹក្សាក្រុង ស្រុក
- ស្នើសុំរាជរដ្ឋាភិបាលផ្តល់ប្រាក់សោធននិវត្តន៍ដល់សមាជិកក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ
- ស្នើបង្កើនចំនួនថវិកាវិភាជន៍របស់ថ្នាក់ជាតិដល់រដ្ឋបាលក្រុងស្រុក ឃុំ សង្កាត់
- សូមថ្នាក់ជាតិបន្ថែមថវិកា ដើម្បីឱ្យក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់អនុវត្តមុខងារ តួនាទី និងភារកិច្ចរបស់ខ្លួនឱ្យបានពេញលេញ

44

## ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់៖ សំណូមពរ (ត)

- ការបង់ពន្ធប្រថាប់ត្រាចូលថវិកាជាតិ សូមបង់ត្រឹមថ្នាក់ក្រុង ស្រុក ឱ្យមានមន្ត្រីរងចាំទទួលថវិកា
- សូមមានវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពសម្រាប់ក្រុមប្រឹក្សា ក្រុង ស្រុក ឃុំ សង្កាត់
- ពេលមានព័ត៌មានថ្មីសូមជួយបណ្តុះបណ្តាលបន្ថែម
- បន្តយន្តការគាំទ្រក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ តាមរយៈការបណ្តុះបណ្តាល និងជំនួយបច្ចេកទេស

45

## ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់៖ សំណូមពរ (ត)

- ផ្តល់វគ្គបណ្តុះបណ្តាលដល់មន្ត្រីបំរុងនឹងទៅបំពេញតួនាទីជាស្មៀន
- រាល់កិច្ចប្រជុំ និង វគ្គបណ្តុះបណ្តាលថ្នាក់ជាតិ និង ថ្នាក់ខេត្ត សូមអោយមានថ្នាក់ដឹកនាំសមាគមបានចូលរួម
- សំណូមពរថ្នាក់ជាតិ ឬថ្នាក់ខេត្តឆ្លើយតបឱ្យទាន់ពេលវេលា ទៅលើបញ្ហាប្រឈម ដែលលើកឡើងនៅក្នុងវេទិកាសាធារណៈ
- បញ្ហាផ្សេងៗ ដែលប្រមូលបានពីវេទិកាថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ សុំបូកសរុបបញ្ចូលគ្នា ហើយដាក់ជូនវេទិកាថ្នាក់ជាតិ
- ការកែតម្រូវទិន្នន័យអត្រានុកូលដ្ឋាន ដែលខុសសូមមានការកែតម្រូវនៅត្រឹមថ្នាក់ខេត្ត និងកំណត់ពេលវេលាច្បាស់លាស់

46

## ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់៖ សំណូមពរ (ត)

- ការកែតម្រូវ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានសុំធ្វើត្រឹមរដ្ឋបាលក្រុង ស្រុក ឬឃុំ សង្កាត់ សាមី
- ការចុះបញ្ជីអត្រានុកូលដ្ឋានមរណៈភាពដែលស្លាប់ឆ្លងឆ្នាំ(ពី០១ឆ្នាំឡើង)ដោយមិនចាំបាច់ប្ដឹងសុំសាលក្រមពីតុលាការក្នុងបញ្ជីអត្រានុកូលដ្ឋានមរណៈភាព
- សំណូមពរឱ្យមន្ទីរជំនាញពាក់ព័ន្ធមានការឆ្លើយតបចំពោះសំណើរបស់ឃុំ សង្កាត់ ជាពិសេសការងារអភិវឌ្ឍន៍ឃុំ សង្កាត់
- សូមឱ្យគ្រប់មន្ទីរជំនាញចុះជួយដល់មូលដ្ឋានផ្ទាល់
- ស្នើសុំផ្ដល់ផ្ទាំងព័ត៌មាន(I4Cs) ឱ្យបានទាន់ពេលកំណត់។

47

## បញ្ហាផ្សេងៗ

- ប្រជាពលរដ្ឋមួយចំនួនធំប្រើប្រាស់ដីធ្លីមិនទាន់មានប័ណ្ណកម្មសិទ្ធិស្របច្បាប់
- បញ្ហាប្រើប្រាស់ និងជួញដូរគ្រឿងញៀននៅតាមឃុំ សង្កាត់
- ការចាក់ឧបករណ៍បំពងសម្លេងហួសម៉ោងកំណត់
- ក្មេងទំនើង ល្បែងស៊ីសង
- បញ្ហារំលោភសេពសន្ថវៈលើកុមារ និងការជួញដូរផ្លូវភេទ
- បញ្ហាគ្រោះថ្នាក់ចរាចរច្រើន ការប្រើប្រាស់រថយន្តគ្មានលក្ខណៈបច្ចេកទេស ការដឹកទំនិញលើសកំណត់ និងការបើកបរគ្មានការប្រុងប្រយ័ត្ន និងហួសល្បឿនកំណត់
- បញ្ហាសម្រាមពាសវាលពាសកាលនៅតាមដងផ្លូវសាធារណៈ

48

## ទិសដៅរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

- ធ្វើការសិក្សាអំពីជំរើសបង្កើតសមាគមរួមមួយដែលមានគណៈអភិបាល និងក្រុមប្រឹក្សា ឬត្រូវមានសមាគមពីរផ្សេងៗ ដោយសមាគមមួយសម្រាប់ក្រុមប្រឹក្សា និងសមាគមមួយទៀតសម្រាប់គណៈអភិបាល
- ពិភាក្សាលទ្ធផលនៃការសិក្សាជាមួយសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្តដែលតំណាងឱ្យ ក្រុមប្រឹក្សារាជធានី ខេត្ត និងសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋានដែលតំណាងឱ្យក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត និងសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋានត្រូវប្រកាន់យកជំរើសដែលបានសិក្សា។

49

## សន្និដ្ឋាន

- បន្ទាប់ពីកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការបានចាប់នៅឆ្នាំ ២០០២ ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិសម្រេចបានសមិទ្ធផលជាច្រើន
- ទន្ទឹមនឹងសមិទ្ធផលដ៏ធំធេងនេះ ក៏នៅមានបញ្ហាប្រឈមជាច្រើនផងដែរ
- ទាមទារឱ្យមានការយកចិត្តទុកដាក់ដោះស្រាយបញ្ហាប្រឈមដែលបានឡើងដោយក្រុមប្រឹក្សា

50

សូមអរគុណ

51